**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**KINGDOM OF CAMBODIA**

Nation - Religion - King

**ក្រសួងពាណិជ្ជកម្ម**

Ministry of Commerce

No. ២២៨ MOC/SM 2009

# ប្រកាស

## ស្តីពី

## ការគ្រប់គ្រងអាជីវកម្មលោហធាតុត្បូងថ្មមានតំលៃជាគ្រឿងអលង្ការ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៩/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស /រកត/០១៩៦/១៦ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម

-បានឃើញព្រះរាជក្រមលេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រម លេខ នស/រកម/០៦៩៥/០៤ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម

-បានឃើញព្រះរាជក្រម លេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីអំពីការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផល ទំនិញ និងសេវា

-បានឃើញអនុក្រឹត្យលេខ ៩១ អនក្រ.បក ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម

-យោងតាមប្រកាសលេខ ធ៩-៩៩-១០០ ប្រក ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩៩ ស្តីពីការគ្រប់គ្រងអាជីវកម្មត្បូងថ្ម និងលោហធាតុមានតំលៃ របស់ធនាគារជាតិនៃកម្ពុជា

-យោងតាមលិខិតលេខ ធ៩.០៩.៥៤៨ សជណ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៩ ស្តីពីការគ្រប់គ្រងអាជីវកម្មលោហធាតុត្បូងថ្មមានតំលៃជាគ្រឿងអលង្ការ របស់ធនាគារជាតិនៃកម្ពុជា

-យោងលិខិតលេខ ១៩៩១ MOC/ SM 2009 ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០០៩ ស្តីពីការគ្រប់គ្រងអាជីវកម្ម លោហធាតុត្បូងថ្មមានតំលៃជាគ្រឿងអលង្ការ របស់ក្រសួងពាណិជ្ជកម្ម

-យោងតាមសេចក្តីជូនដំណឹងលេខ ធ៩.០៩.៦០១ សជណ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៩ ស្តីពីការបញ្ឈប់ការផ្តល់លិខិតអនុញ្ញាតប្រកបអាជីវកម្មលោហធាតុត្បូងថ្មមានតំលៃជាគ្រឿង អលង្ការ របស់ធានាគារជាតិនៃកម្ពុជា

-យោងតាមការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

## សម្រេច

**ប្រការ ១** : កំណត់ល័ក្ខខ័ណ្ឌនៃការគ្រប់គ្រងអាជីវកម្ម លោហធាតុត្បូងថ្មមានតំលៃជាគ្រឿងអលង្ការ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។ លោហធាតុត្បូងថ្មមានតំលៃជាគ្រឿងអលង្ការ ត្រូវបានចាត់ទុកជាទំនិញមួយប្រភេទដែលធ្វើចរាចរនៅលើទីផ្សារដូចប្រភេទទំនិញដ៏ទៃទៀត ។

**ប្រការ ២** : រាល់អាជីវករ ពាណិជ្ជករ និងក្រុមហ៊ុនទាំងឡាយ ដែលធ្វើអាជីវកម្មលោហធាតុមានតំលៃជាគ្រឿងអលង្ការ ត្រូវមកសុំការអនុញ្ញាតពីក្រសួងពាណិជ្ជកម្ម :

- អាជីវករ ពាណិជ្ជករ ដែលមិនជាប់ពន្ធលើប្រាក់ចំណេញ ត្រូវមកសុំលិខិតអនុញ្ញាតពីនាយកដ្ឋានជំរុញពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម

- ដោយឡែក ចំពោះអាជីវករ ពាណិជ្ជករ ដែលជាប់ពន្ធលើប្រាក់ចំណេញ ត្រូវមកសុំចុះបញ្ជីពាណិជ្ជកម្មនៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្មជាមុនសិន មុននឹងស្នើសុំលិខិតអនុញ្ញាតពីនាយកដ្ឋានជំរុញពាណិជ្ជកម្ម

- ទំរង់បែបបទនៃការសុំប្រកបអាជីវកម្ម ត្រូវមកទំនាក់ទំនងនៅមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត ដែលអាជីវករ ពាណិជ្ជករនោះតាំងនៅ ។

**ប្រការ ៣** : អាជីវករ ពាណិជ្ជករ ដែលបានទទួលការអនុញ្ញាតឱ្យប្រកបអាជីវកម្មលោហធាតុត្បូងថ្មមានតំលៃជាគ្រឿងអលង្ការ ត្រូវប្រកបមុខរបររបស់ខ្លួននៅក្នុងទីតាំងដែលអាជ្ញាធរមានសមត្ថកិច្ចបានកំណត់ ត្រូវបិទស្លាកថ្លៃលើគ្រឿងអលង្ការនីមួយៗឱ្យបានច្បាស់លាស់ និងត្រូវមានវិក្កយបត្រជូនអតិថិជន រាល់ការលក់។ វិក្កយបត្រត្រូវមានបញ្ជាក់អំពី នាមករណ៍ អាសយដ្ឋានអាជីវកម្ម លេខទូរស័ព្ទ និងកំណត់សំគាល់ផ្សេងៗទៀត។

**ប្រការ ៤** : អាជីវករ ពាណិជ្ជករ ដែលបានធ្វើអាជីវកម្មលោហធាតុត្បូងថ្មមាន តំលៃជាគ្រឿងអលង្ការ ត្រូវធ្វើការបញ្ជាក់ឱ្យបានច្បាស់លាស់នូវគុណភាពរបស់ផលិតផលខ្លួន នៅលើវិក្កយបត្រដែលបានផ្តល់ជូនអតិថិជន។ អាជីវករ ពាណិជ្ជករទាំងឡាយណាដែលបានក្លែងបន្លំ ភូតភរ រំលោភសេចក្តីទុកចិត្ត ឬឆបោកអតិថិជនត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។

**ប្រការ ៥** : លិខិតអនុញ្ញាតឱ្យប្រកបអាជីវកម្មលោហធាតុត្បូងថ្មមានតំលៃជាគ្រឿងអលង្ការ ដែលចេញដោយ

ក្រសួងពាណិជ្ជកម្មមានសុពលភាពសំរាប់រយៈពេល ១២ខែ គិតចាប់ពីថ្ងៃផ្តល់ជូន។អាជីវករ ពាណិជ្ជករ ដែលបន្តអាជីវកម្មរបស់ខ្លួនត្រូវដាក់ពាក្យសុំជាថ្មី ក្នុងរយៈពេល៣០ថ្ងៃយ៉ាងយឺតបំផុត មុនថ្ងៃផុតកំណត់សុពលភាពនីមួយៗ។

**<u>ប្រការ៦</u>** : លិខិតអនុញ្ញាតឱ្យប្រកបអាជីវកម្មលោហធាតុត្បូងមានតំលៃជាគ្រឿងអលង្ការនេះ ត្រូវដកហូតវិញមុនសុពលភាព ក្នុងករណីដែលអាជីវករ ពាណិជ្ជករ មិនគោរពតាមកិច្ចសន្យាសុំប្រកបអាជីវកម្មលោហធាតុត្បូងថ្មមានតំលៃ ជាគ្រឿងអលង្ការ និងមិនគោរពតាមខ្លឹមសារក្នុងប្រការ៣ និងប្រការ៤ នៃប្រកាសនេះ។

**<u>ប្រការ ៧</u>** : ក្នុងករណីផ្អាក ឬបញ្ឈប់សកម្មភាព ឬប្តូរទីតាំងអាជីវកម្ម អាជីវករ ពាណិជ្ជករ ត្រូវធ្វើការជូនដំណឹងជាលាយលក្ខណ៍អក្សរ មកក្រសួងពាណិជ្ជកម្មឱ្យបានមុន ៣០ ថ្ងៃ។

**<u>ប្រការ ៨</u>** : អាជីវករ ពាណិជ្ជករ ដែលធ្វើអាជីវកម្មលោហធាតុត្បូងថ្មមានតំលៃជាគ្រឿងអលង្ការ មិនគោរពតាមប្រកាសនេះ នឹងត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

**<u>ប្រការ ៩</u>** : ចំពោះនីតិវិធី និង ទំរង់បែបបទនៃការស្នើសុំធ្វើអាជីវកម្មលោហធាតុត្បូងថ្មមានតំលៃជាគ្រឿងអលង្ការ ត្រូវបានកំណត់តាមសេចក្តីណែនាំដោយឡែករបស់ក្រសួងពាណិជ្ជកម្ម។

**<u>ប្រការ ១០</u>** : ប្រកាស និងបទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនិងប្រកាសនេះត្រូវចាត់ទុកជា និរាករណ៍ ។

**<u>ប្រការ ១១</u>** : នាយិកាខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋាន ពាក់ព័ន្ធនិង ប្រធានមន្ទីរពាណិជ្ជកម្ម រាជធានី-ខេត្ត ត្រូវអនុវត្តតាម ប្រកាសនេះ ។

**<u>ប្រការ ១២</u>** : ប្រកាសនេះមានប្រសិទ្ធភាព និងអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ; ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ២០០៩

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

**<u>ចម្លងជូន</u>**

-ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
-ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង**
-ខុទ្ទកាល័យ លោកជំទាវឧបនាយករដ្ឋមន្ត្រីប្រចាំការ **ម៉ែន សំអន**
-ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **គាត ឈន់**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងទេសចរណ៍
-ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ
-ក្រសួងព័ត៌មាន
-ធនាគារជាតិនៃកម្ពុជា
“<u>ដើម្បីជ្រាបជាព័ត៌មាន</u>”
-សាលារាជធានី-ខេត្ត “<u>ដើម្បីសហការអនុវត្ត</u>”
-ដូចប្រការ១១ “<u>ដើម្បីអនុវត្ត</u>”
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ